# [សំខាន់] ប្រការប្រុងប្រយ័ត្ននៅថ្ងៃប្រលង

កម្រិតឯកទេស

## 1. អំពីការផ្លាស់ប្តូរសម្លៀកបំពាក់

សូមកុំផ្លាស់ប្តូរសម្លៀកបំពាក់ រហូតដល់អនុរក្សប្រលងណែនាំ។
សូមពាក់សម្លៀកបំពាក់ការងារ អាវនិងស្លៀកខោ នៅទីតាំងដែលកំណត់ដោយOTAFF
ហើយសូមពាក់អាវយឺតពីក្នុងសម្លៀកបំពាក់ការងារ។(មួកគឺជាលំហាត់នៃការប្រលងនឹងអោយពាក់នៅពេលក្រោយ។)

## 2. អំពីការគ្រប់គ្រងរបស់មានតម្លៃ

**ដោះគ្រឿងអលង្ការចេញ**

សូមដោះចេញនូវគ្រឿងអលង្ការទាំងអស់គ្រប់ប្រភេទ

ហើយដាក់ក្នុងកាបូប។



**ការគ្រប់គ្រងរបស់មានតម្លៃ**

របស់មានតម្លៃគឺគ្រប់គ្រងដោយខ្លួនឯង។

សូមធ្វើយ៉ាងណាកុំឱ្យមានរបស់ភ្លេច ឬរបស់ជ្រុះជាដើម។



**កុំឱ្យមានអ្វីក្នុងហោប៉ៅ**

សូមកុំដាក់អ្វីចូលក្នុងហោប៉ៅឱ្យសោះ។



## 3. អំពីប្រការប្រុងប្រយ័ត្នក្នុងអគារមណ្ឌល

**សុជីវធម៌**

មិនត្រូវខ្សឹបខ្សៀវគ្នានៅអគារមណ្ឌល ឬមណ្ឌលប្រលងទេ។

មិនត្រូវធ្វើសកម្មភាពណាដែលបង្កការរំខានដល់អ្នកជុំវិញខ្លួនទេ។

**ត្រូវបិទឧបករណ៍អេឡិចត្រូនិក**

សូមបិទឧបករណ៍អេឡិចត្រូនិក ដូចជាស្មាតហ្វូនជាដើម

ហើយដាក់ក្នុងកាបូប។




**ហាមថត**

ការថតរូប ឬថតវីដេអូនៅអគារមណ្ឌល ឬមណ្ឌលប្រលងគឺហាមឃាត់។

* អ្នកដឹកនាំទៅ ក៏ហាមឃាត់ដែរ។



**ការប្រើបន្ទប់ទឹក**

ការផ្លាស់ប្តូរសម្លៀកបំពាក់ ហូបឬផឹក នៅក្នុងបន្ទប់ទឹកគឺហាមឃាត់។



# [សំខាន់] ប្រការប្រុងប្រយ័ត្ននៅថ្ងៃប្រលង

## 4. អំពីការចុះឈ្មោះ

**ការបញ្ជាក់អត្តសញ្ញាណសាមីខ្លួន**

យើងនឹងឲ្យអ្នកដោះម៉ាស់ និងវ៉ែនតាចេញ ដើម្បីពិនិត្យបញ្ជាក់ មុខរបស់អ្នក។



**ការសរសេរលើដៃ**

យើងនឹងពិនិត្យបញ្ជាក់ថា អ្នកបានសរសេរនៅលើបាតដៃ និងខ្នងដៃឬទេ។



## 5. អំពីរបៀបសរសេរឈ្មោះជាដើម នៅលើសំណួរប្រលង

* សំណួរប្រលងដែលត្រូវបានចែកនៅថ្ងៃនោះ សរសេរដោយភាសាជប៉ុនទាំងអស់។




កាលបរិច្ឆេទប្រលង សូមសរសេរដោយមើលលើក្ដារខៀននៅក្នុងមណ្ឌលប្រលង។

សូមសរសេរអត្តលេខប្រលង និងឈ្មោះដោយមើលប័ណ្ណប្រលង។



# [សំខាន់] ប្រការប្រុងប្រយ័ត្ននៅថ្ងៃប្រលង

## 6. អំពីរបៀបឆ្លើយសំណួរសរសេរ

(1) នៅពេលក្រដាសសំណួរត្រូវបានចែក សូមកុំបើករហូតដល់មានការណែនាំ។

(2) នៅពេលមានការណែនាំ សូមបើកក្រដាសសំណួរ ហើយបត់វាជាពីរ។

(3) នៅពេលធ្វើសំណួរនៅផ្នែកខាងក្រោយ ក៏ត្រូវបត់ក្រដាសសំណួរប្រលងជាពីរដែរ។




(4) នៅពេលដល់ម៉ោង សូមដាក់ក្រដាសផ្នែកមុខបែរទៅលើ។ អនុរក្សប្រលងនឹងប្រមូលក្រដាសសំណួរ។

### របៀបសរសេរនៅក្រឡោនចម្លើយ

がっかしけん
**★学科試験**

សូមជ្រើសរើសចម្លើយដែលគិតថាត្រឹមត្រូវពីក្នុងជម្រើស ហើយសូមសរសេរដោយលេខសម្គាល់។

ឧទាហរណ៍) 1. ប៉ោម 2. ចេក 3. ក្រូចឃ្វិច

かいとうらん
解答欄
1

じつぎ はんだんとうしけん
**★実技判断等試験**

សូមជ្រើសរើសចម្លើយដែលគិតថាត្រឹមត្រូវពីក្នុងជម្រើស ហើយសូមសរសេរដោយអក្សរអង់គ្លេស។

ឧទាហរណ៍) A. ប៉ោម B. ចេក C. ក្រូចឃ្វិច

かいとうらん
解答欄
A

じつぎ けいかくりつあんとうしけん
**★実技計画立案等試験**

សូមជ្រើសរើសចម្លើយដែលគិតថាត្រឹមត្រូវពីក្នុងជម្រើស ហើយសូមសរសេរដោយអក្សរអង់គ្លេស។

ឧទាហរណ៍) A. ចំនួន10 B. ចំនួន100 C. ចំនួន1000

かいとうらん
解答欄
A

* អាចប្រើម៉ាស៊ីនគិតលេខបានក្នុងការប្រលងនេះ។

* សរសេរប្រមាណវិធីគណនា នៅលើប្រឡោះទំនេរឬចំហៀងខាងក្រោយនៃក្រដាសសំណួរ ក៏បានដែរ។ សូមកុំសរសេរនៅលើអ្វីផ្សេងក្រៅពីក្រដាសសំណួរ។

ប្រមាណវិធីគណនាដែលបានសរសេរ មិនចាំបាច់លុបក៏បានដែរ។

せいさくとうさぎょうしけん
## 7. ស្ដីអំពីរបៀបបន្តនៃ 製作等作業試験

(1) នឹងមានការពន្យល់ពីសម្ភារដាក់ឲ្យខ្ចី និងអ្វីដែលពាក់ព័ន្ធនឹងការប្រលងផ្សេងទៀត។

(2) អនុរក្សប្រលងនឹងនិយាយថា (សូមចាប់ផ្ដើម“Hajimetekudasai”)។

(3) សូមបន្តការធ្វើម្ហូប ដោយមើលក្រដាសសំណួរបណ្ដើរ (作業手順書)។ (さぎょうてじゅんしょ)

(4) ក្រោយបញ្ចប់ការប្រលង សូមប្រគល់សងសម្ភារដាក់ឲ្យខ្ចី ទៅកាន់អនុរក្សប្រលងវិញ ឲ្យបានជាដាច់ខាត។

## 8. អំពីសកម្មភាពមិនត្រឹមត្រូវ

**នៅពេលគេរកឃើញថា អ្នកបានធ្វើសកម្មភាពដូចខាងក្រោម នោះអ្នកនឹងត្រូវអស់សិទ្ធិប្រលង (នឹងត្រូវធ្លាក់)។ សូមប្រុងប្រយ័ត្នឲ្យបានគ្រប់គ្រាន់។**

### លួចចម្លង



មិនត្រូវមើលចម្លើយរបស់អ្នកដទៃទេ។

### ប្រាប់គេ ឬ គេប្រាប់




មិនត្រូវប្រាប់ចម្លើយទៅអ្នកនៅជុំវិញ ឬជួយគ្នាទេ។

### និយាយ



មិនត្រូវនិយាយម្នាក់ឯង ឬនិយាយជាមួយអ្នកនៅជុំវិញទេ។

### ដើរចេញពីកន្លែងអង្គុយដោយគ្មានការអនុញ្ញាត



នៅពេលដើរចេញពីកៅអីអង្គុយ សូមលើកដៃ ហើយប្រាប់ដល់អនុរក្សប្រលង។

### យកចេញ ឬ សរសេរចម្លង




មិនត្រូវយកក្រដាសសំណួរឬចម្លើយចេញទេ
មិនត្រូវសរសេរចម្លងលើប័ណ្ណប្រលង ឬលើដៃជាដើមទេ។

### មើលការកត់ត្រា



មិនត្រូវមើលឯកសាររៀន ឬការកត់ត្រាជាដើម នៅពេលកំពុងប្រលងទេ។

**ទោះជានៅមុនពេលចាប់ផ្តើមការប្រលងក៏ដោយ ក្នុងករណីមានសរសេរអក្សរឬលេខ នៅលើប័ណ្ណប្រលងឬនៅលើដៃជាដើម គេនឹងចាត់ទុកថាជាសកម្មភាពមិនត្រឹមត្រូវ។ សូមប្រុងប្រយ័ត្នឲ្យបានគ្រប់គ្រាន់។**

## 9. ប្រការប្រុងប្រយ័ត្នពេលកំពុងប្រលង

### នៅពេលមានអាការៈមិនស្រួល



នៅពេលមិនស្រួលខ្លួន សូមលើកដៃហើយប្រាប់ដល់អនុរក្សប្រលង។

### នៅពេលកើតមានគ្រោះមហន្តរាយ ដូចជារញ្ជួយដីឬអគ្គិភ័យជាដើម



សូមគេចខ្លួនទៅតាមការណែនាំរបស់អនុរក្សប្រលង។